**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៧៧៧៧ ព.ណ.ភ.ឈម.

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ស៊ីអេសអេច បេវើរីច (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលភេសជ្ជៈម៉ាក OISHI Green Tea ដែលមានភ្ជាប់ចំណុះមកជាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ស៊ីអេសអេច បេវើរីច (ខេមបូឌា) ឯ.ក**។

**យោង:** - មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **ស៊ីអេសអេច បេវើរីច (ខេមបូឌា) ឯ.ក** ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន OISHI GROUP PUBLIC COMPANY LIMITED. ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន OISHI TRADING CO., LTD. ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២១០៤៩/០៥ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលភេសជ្ជៈពាក់ម៉ាកខាងលើរបស់ក្រុមហ៊ុន **ស៊ីអេសអេច បេវើរីច (ខេមបូឌា) ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន OISHI GROUP PUBLIC COMPANY LIMITED. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០២៤ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន OISHI GROUP PUBLIC COMPANY LIMITED. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

***<u>ចម្លងជូន:</u>***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ* ***សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត*** *នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ-កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# បញ្ជី

## ប្រភេទ និងចំណុះទំនិញកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល នឹងចែកចាយផ្តាច់មុខ

## ភេសជ្ជៈម៉ាក OISHI Green Tea

| ល.រ | ចំណុះ |
|---|---|
| 1 | 320 ML |
| 2 | 380 ML |
| 3 | 500 ML |
| 4 | 800 ML |